media release

ABC Radio Australia

Thursday, 30 October 2008

# សេចក្តីប្រកាសព័ត៌មានពីទីក្រុងម៉ែលប៊ិន

## វិទ្យុអូស្ត្រាលីធ្វើការផ្សាយផ្ទាល់ដើម្បីអបអរសាទរពរាជពិធីបុណ្យអុំទូកនៅប្រទេសកម្ពុជានៅក្នុងខែវិច្ឆិកានេះ។

បើសិនជាលោកអ្នកមានបំណងអញ្ជើញទៅទស្សនាពិធីបុណ្យអុំទូកនៅរាជធានីភ្នំពេញឆ្នាំនេះ សូមអញ្ជើញមកទស្សនាការផ្សាយនៃកម្មវិធីខេមរភាសា និងភាសាអង់គ្លេសនៃវិទ្យុអូស្ត្រាលី ដែលនឹងធ្វើការផ្សាយផ្ទាល់ពីទីក្រុងភ្នំពេញនៅថ្ងៃពុធ ទី១២ និងថ្ងៃព្រហស្បតិ៍ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៨នៅមាត់ទន្លេមុខវត្តឧណ្ណាលោម។

ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM102) និងវិទ្យុ FMជាតិ ៩៦ផងនោះ ការផ្សាយនឹងចាប់ផ្តើមនៅម៉ោង៧ព្រឹក ជាមួយនឹងកម្មវិធី Breakfast Club ដែលមានអ្នកនាងអាឌីឡែន អ៊ឹងជាពិធីករ រួមនិងការចែកជូននំប៉័ងដាក់សាច់ជាអាហារពេលព្រឹកដោយឥតគិតថ្លៃ ដល់ទស្សនិកជនដែលអញ្ជើញមកទស្សនាការផ្សាយផ្ទាល់នៅមាត់ទន្លេ មុខវត្តឧណ្ណាលោម មុនម៉ោង៧ព្រឹកទាំងពីរថ្ងៃនេះ។

នៅក្នុងថ្ងៃទី១ លោកអ្នកនឹងបានទស្សនាការសម្តែងរបស់តារាចម្រៀងរ៉ុក គឺលោកJames និងកញ្ញានីដា អមដោយវង់តន្ត្រីចចកសមុទ្រ ក៏ដូចជាការសម្តែងអាយ៉ៃរៀបចំឡើងដោយវិទ្យុ FM102 មុននឹងឈានចូលដល់កម្មវិធីភាសាខ្មែរ។ អ្នកស្រី ប៊ុន ឡឺរីសីដា ប្រធានកម្មវិធីខេមរភាសានៃវិទ្យុអូស្ត្រាលី និងជាបេក្ខជនផ្តាច់ព្រ័ត្រ សម្រាប់រង្វាន់កិត្តិយសឆ្នាំ ២០០៧ ក្នុងឋានៈជាពលរដ្ឋគំរូអូស្ត្រាលី នឹងធ្វើការផ្សាយផ្ទាល់ជាខេមរភាសារយៈពេល១ម៉ោងនាពេលថ្ងៃត្រង់។ នៅពេលនោះ លោកអ្នកនឹងអាចសំណេះសំណាលជាមួយនឹងតារាចម្រៀងរ៉ុក និងវង់តន្ត្រីចចកសមុទ្រ។

សម្រាប់ថ្ងៃទី២ លោកអ្នកក៏អាចចូលរួមការប្រឡងចម្រៀងខារ៉ាអូខេ រៀបចំឡើងដោយវិទ្យុជាតិ FM96 ក្នុងគោលបំណងបង្ហាញមុខមាត់អនាគតតារាថ្មីៗ ដោយមានការប្រគល់រង្វាន់ជូនជ័យលាភី៥នាក់និងរង្វាន់អនុស្សាវរីយ៍លើកទឹកចិត្តដល់បេក្ខជនដែលចូលរួមប្រឡងផងដែរ។ ដូច្នេះសូមអញ្ជើញមកចុះឈ្មោះឲ្យបានរួសរាន់មុនម៉ោង៧ព្រឹក។ ក្រៅពីនេះ លោកវេជ្ជបណ្ឌិត លីចេងហ៊ុយ ស្ថាបនិកនៃទស្សនាវដ្តីសុខភាពយើង នឹងចូលរួមកម្មវិធីថ្ងៃត្រង់ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ទស្សនិកជនពាក់ព័ន្ធនឹងបញ្ហាសុខភាព។

យើងខ្ញុំសង្ឃឹមថា លោកអ្នកនាងកញ្ញានឹងអញ្ជើញមកចូលរួមទស្សនាការផ្សាយផ្ទាល់របស់វិទ្យុអូស្ត្រាលីនាព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែនេះ ដើម្បីរួមចំណែកអបអរសាទរពិធីបុណ្យជាតិ ក៏ដូចជាការលើកស្ទួយប្រពៃណីជាតិខ្មែរផងដែរ។ វិទ្យុអូស្ត្រាលីខេមរភាសាធ្វើការផ្សាយជារៀងរាល់ថ្ងៃស្ទើរតែពាសពេញផ្ទៃប្រទេសកម្ពុជា តាមរយៈវិទ្យុFM ក្នុងស្រុក (FM102 នៅភ្នំពេញ, FM101.5 នៅសៀមរាប, FM92.75 នៅបាត់ដំបង, FM96.5 នៅបន្ទាយមានជ័យ, FM98.5 នៅក្រចេះ, FM89.5 នៅរតនគិរី , FM90.5 នៅប៉ៃលិន ហើយនៅដំណាច់ឆ្នាំនេះ ការផ្សាយរបស់វិទ្យុអូស្ត្រាលីខេមរភាសានឹងមានផ្សាយនៅតាម FM99.5 នៅកោះកុង និង FM99.70 នៅកំពត)។ រីឯការផ្សាយជាភាសាអង់គ្លេស២៤ម៉ោងមានជូនតាមរយៈវិទ្យុFM101.5 នៅរាជធានីភ្នំពេញ និងខេត្តសៀមរាបផងដែរ។

ចំពោះព័ត៌មានបន្ថែមសូមចូលទៅវ៉ិបសាយថ៍: radioaustralia.net.au

---

**Media contact:**

Mark Hemetsberger, Marketing Strategist, ABC RADIO AUSTRALIA, Tel: +61 3 9626 1723, Mob: +61 4 3894 7523. Sar Sovannara in Phnom Penh, Mob: 855 (0)12 856 918

media release

ABC Radio Australia

## RADIO AUSTRALIA CELEBRATIONS

**Day1 : 12 November 2008**

| Time | Program | Presenters |
|---|---|---|
| 7am to 9am | English Breakfast Club | Adelaine Ng |
| 9.15am 10:15 am | Live performance from Sea-Wolf and Rock Stars | Rock Productions |
| 10:15am to 10:45am | Folk singers (Ayay) | FM102 Women's Media Centre |
| 10:45 am to 12 noon | More live performance from Sea-wolf and Rock Stars | Rock Productions |
| 12 noon to 1pm | Radio Australia's Khmer program | Seda and Phannapha FM102 |

**Day2 : 13 November 2008**

| Time | Program | Presenters |
|---|---|---|
| 7am to 9am | English Breakfast Club | Adelaine |
| 9am 12 noon | Karaoke competition | FM96 |
| 12 noon to 1pm | Radio Australia's Khmer program | Seda and Phannapha FM102 |

*** Note: Proposed schedule is subject to change without notice.**